# ដំណាំល្មុត



## ១- ពូជល្មុត:

ក- ល្មុតធម្មតា ឬ ល្មុតណាំងបាយស្រោះៈផ្លែវាធំល្មម រាងទ្រវែង ផ្លែ៤ ទៅ៥ដងក្នុងមួយឆ្នាំ។

ខ-ល្មុតណាំង ឬ ល្មុតណាំងថ្ម ឬ ល្មុតថ្មៈ ផ្លែល្អិតៗ ប៉ុន្តែរឹង វាផ្លែ២ ទៅ ៣ដង ក្នុងមួយឆ្នាំ។

គ- ល្មុតពូជចឹកកាយ៉ាំង ឬល្មុតតាខ្មៅៈ ផ្លែធំៗ វាផ្លែ ៤ ទៅ ៥ដងក្នុងមួយឆ្នាំ ប៉ុន្តែពុំសូវមានរសជាតិឆ្ងាញ់ទេ។ គេនិយមប្រើប្រាស់វាក្នុងពិធីមង្គលការ និង បុណ្យទានផ្សេងៗ។

ឃ-ល្មុតណាំងប៉ែន ឬល្មុតណាំងខ្សាច់ៈផ្លែមានរាងដូចផ្លែចាន់ប៉ែន សាច់វាទន់ជ្រាកៗបន្តិច ` ផ្លែវាធំជាង ល្មុតធម្មតាបន្តិច វាផ្លែ៤ទៅ ៥ដងក្នុងមួយឆ្នាំ។

## ២- ការរៀបចំដី និរណ្តៅដាំល្មុត:

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ ខែទៅ ១ ខែកន្លះសិន ដើម្បីអោយងាប់សត្វល្អិត និងស្មៅ រលួយបានល្អ។ យើងត្រូវភ្ជួរដីមួយលើកទៀតនៅ ពេលដែលជិតដាំកូនល្មុត។
- យើងត្រូវទាញខ្សែអោយត្រង់ដើម្បីងាយស្រួលក្នុងការដាំដំណាំផ្សេងទៀត ក្រោមដើមល្មុត។
- ចន្លោះពីដើមមួយ ទៅដើមមួយ មានប្រវែង៥ម៉ែត្រ
- កាប់រណ្តៅទំហំ ៤តឹកបួនជ្រុង និងជំរៅ ៤តឹកកាប់ យកអាចម៍ដីចេញពាក់កណ្តាលរណ្តៅ រួចទើបកាប់ បំផុសអាចម៍ដីនៅសល់អោយម៉ដ្ត រួចដាក់លាយជា មួយដីអាចម៍គោពុកផុយល្អ។
- ត្រូវហាលរណ្តៅទុកចោល ២ទៅ៣ថ្ងៃមុនដាំ។




## ៣- ការដាំកូនល្មុត:

- យើងត្រូវយកមែកល្មុត (មែកសាក) មកទុកនៅក្បែរៗរណ្តៅជាមុនសិន។
- យកមែកល្មុតសាកមកត្រាំទឹកឲ្យសើមបន្តិច។
- ស្រាយកញ្ចប់ផ្លាស្ទិចចេញយឺតៗដោយថ្នមៗ និងប្រុងប្រយ័ត្នជានិច្ច ដោយកុំឲ្យបែកអាចម៍ដី និងដាច់ឫសល្មុតដែលបណ្តាលឲ្យវាងាប់បាន។



- ត្រូវដាក់មែកល្មុតសាក ចូលទៅក្នុងរណ្តៅដោយថ្នមៗ ដៃម្ខាងទៀតត្រូវ ប្រមូលអាចម៍ដីលុបរណ្តៅដោយច្របាច់ដី អោយបានតូចៗលុបរោយ បំពេញ រណ្តៅដោយកប់ ដីឫស





កំរាស់ ២ធ្នាប់ដៃ ហើយនៅសល់ប្រហែល២ធ្នាប់ដៃទៀតទើបអាចម៍ដីស្មើនឹង មាត់រណ្តៅ។

- យើងមិនត្រូវជាន់បង្ហាប់ដីនៅក្នុងរណ្តៅនោះទេ។

❋ យើងត្រូវបោះបង្គោល ២ ឬ ៣ ដើម ចងភ្ជាប់នឹងមែកល្មុត ដើម្បីឲ្យវាមានជំហរត្រង់ និងរឹងមាំ។

❋ យើងត្រូវស្រោចទឹកអោយសើមល្មម ដោយយកដៃ ទទះទឹក ដូចជាស្រោចទឹក លើកូនស្ពៃ។

| អាយុដើមល្មុត | ចំនួនពេលស្រោចទឹក |
| --- | --- |
| តិចជាង១ខែ | រៀងរាល់ថ្ងៃពេលល្ងាច |
| ១ខែ ដល់ ២ខែ | រៀងរាល់ ២ថ្ងៃម្តង |
| ២ខែ ដល់ ៥ខែ | រៀងរាល់ ៣ថ្ងៃម្តង |
| ៥ខែ ដល់ ១ឆ្នាំ | រៀងរាល់១សប្តាហ៍ម្តង |
| ១ឆ្នាំ ដល់ | រៀងរាល់ |
| ៣ឆ្នាំ | ២សប្តាហ៍ម្តង |

## ៤- ការថែទាំដើមល្មុត:

❋ ដើមល្មុតដែលទើបដាំរួច មិនត្រូវប៉ះពាល់ ឬបេះត្រួយស្លឹក ឬកាច់មែកបានទេហើយក៏មិនត្រូវ អោយសត្វពាហនៈញាំញីរទេដែលនាំឲ្យដើម ល្មុតងាប់ ដោយសារតែឫសវាងាយដាច់ណាស់។

❋ ត្រូវតាមដាន និងកំចាត់ដង្កូវស៊ីដើមល្មុតចេញ។ ដង្កូវនេះវាស៊ីតែមែកឬដើមល្មុតទេ។ វាស៊ីពីលើចុះមកក្រោម វាអាចរស់នៅក្នុង មែកល្មុតបានប្រហែល ៤-៥ សប្តាហ៍។

❋ បើសង្កេតឃើញមានអាចម៍ដង្កូវនៅតាមមែកល្មុត យើងត្រូវឆ្កើះសំបកមែករហូតដល់ឃើញដង្កូវនឹងញិចសម្លាប់វាចោល។

## ៥- ការប្រមូលផលផ្លែល្មុត:

❋ ចាប់ពី ៣ឆ្នាំឡើងទៅ យើងអាចប្រមូលផលបានខ្លះៗ។ ចាប់ពី៥ឆ្នាំឡើងទៅ ក្នុង១ដើមយើងអាច ប្រមូលផលបាន ១០០ គក្រ ក្នុងមួយឆ្នាំ។

❋ ជាធម្មតាផ្លែល្មុតចាស់អាចបេះយកមកបន្ទុំបានដោយសង្កេតមើលសំបកផ្លែរលោង ឬយើងកោស លើផ្លែ វាមានពណ៌លឿងត្នោត។

## ឯកសារពិគ្រោះ៖


- Traing module on fruit tree production, 2013
  (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់ពាយព្យ)
- បទពិសោធន៍ ឡុច ឡាច កសិករដាំល្មុត, 2010
  (ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង)



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧





ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម


# បទពិសោធន៍ជោគជ័យ ក្នុងការដាំល្មុតរបស់កសិករគំរូ




សហការផលិតដោយ៖
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប
ឆ្នាំ២០១៣